ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ២០២១

នៅក្នុងខែមេសានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១- មុខងារនីតិកម្ម

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន៧០ច្បាប់
- បានធ្វើកំណត់បង្ហាញព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរណែនាំ ប្រកាស របាយការណ៍ និងលិខិតផ្សេងៗចំនួន១៣ច្បាប់
- បានធ្វើឯកសារពាក់ព័ន្ធនឹងការពន្យាពេលសម័យប្រជុំព្រឹទ្ធសភា
- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចៗ

### ២- មុខងារតំណាង

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រគល់អង្ករចំនួន១០តោន ម៉ាស ទឹកអាល់កុលលាងដៃសម្លាប់មេរោគ និងអំណោយមួយចំនួនជូនសង្កាត់ទាំង១០ ក្នុងក្រុងតាខ្មៅ និងរដ្ឋបាលស្រុកអង្គស្នួល ខេត្តកណ្តាល សម្រាប់ចែកជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដែលជួបការលំបាក និងខ្វះខាត ក្នុងអំឡុងពេលដែលរាជរដ្ឋាភិបាលដាក់ចេញនូវវិធានការបិទខ្ទប់ រឹតបន្តឹង ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងចូលរួមគោរពវិញ្ញាណក្ខន្ធ ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន០៤លើក



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: sum_sorith@camnet.com.kh

- បានរៀបចំ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយ គ្រឿងឧបភោគ បរិភោគ ម៉ាស ជែល ទឹកអាល់កុល លាងដៃសម្លាប់មេរោគ ព្រមទាំងថវិកាមួយចំនួនឧបត្ថម្ភជូនអាជ្ញាធរមូលដ្ឋាន សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ ប៉ុស្តិ៍រដ្ឋបាល កងកម្លាំង ក្រុមគ្រូពេទ្យស្ម័គ្រចិត្តដែលបានចុះជួយក្នុងយុទ្ធនាការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ និងប្រជាពលរដ្ឋមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក ព្រមទាំងចុះពិនិត្យដំណើរការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ជាពិសេសផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល និងសារាចរណែនាំ សេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ កំពត កែប កំពង់ស្ពឺ ព្រះសីហនុ កំពង់ឆ្នាំង កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ សៀមរាប បាត់ដំបង ក្រចេះ ស្វាយរៀង និងខេត្តបន្ទាយមានជ័យចំនួន៧៣លើក

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋ ឈ្វេងយល់អំពីស្ថានភាពរស់នៅ និងការប្រកបរបរទទួលទានរបស់បងប្អូនប្រជាពលរដ្ឋ ការគ្រប់គ្រងប្រជាពលរដ្ឋរបស់មូលដ្ឋានឃុំ និងវិធានការការពារជំងឺកូវីដ-១៩ តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

- បានរៀបចំអំណោយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ សម្រាប់សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការព្រឹទ្ធសភាជាតំណាង ចុះចែកជូនប្រជាពលរដ្ឋមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័កចំនួន១,១៧៩គ្រួសារ នៅសង្កាត់បឹងរាំង សង្កាត់ស្ទឹងមានជ័យទី១ និងសង្កាត់ស្ទឹងមានជ័យទី២ រាជធានីភ្នំពេញ

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយ និងថវិកាមួយចំនួនឧបត្ថម្ភជូនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលកំពុងធ្វើចត្តាឡីស័ក និងរស់នៅតំបន់ក្រហមចំនួន៣៣នាក់

- បានឧបត្ថម្ភថវិកាមួយចំនួនជូនកាកបាទក្រហមកម្ពុជា និងសមាគមចលនាវប្បធម៌ជាតិដើម្បីកុមារកំព្រា កុមារក្រីក្រ ព្រមទាំងថ្លែងអំណរគុណ និងលើកទឹកចិត្តដល់ក្រុមគ្រូពេទ្យព្រះអង្គឌួងដែលបានចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ជូនសមាជិកព្រឹទ្ធសភា មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានទទួលពាក្យបណ្ដឹងចំនួន០៤ករណី ផ្ញើលិខិតអន្តរាគមន៍ទៅក្រុមមេធាវីស្ម័គ្រចិត្តសម្ដេចតេជោសែន ដើម្បីដោះស្រាយចំនួន០១ករណី និងកំពុងពិនិត្យសិក្សាបានចំនួន០៦ករណី

- បានផ្សព្វផ្សាយខ្សែវីដេអូអំពីសមិទ្ធផលរយៈពេល១ឆ្នាំរបស់ព្រឹទ្ធសភា (២០២០-២០២១)

- បានផលិតទស្សនាវដ្ដីប្រចាំខែមេសា ឆ្នាំ២០២១ ចំនួន៨០០ក្បាល

- បានផលិត និងចាត់ចែងបញ្ជូនសារថ្វាយព្រះពរ សារជូនពរ ប័ណ្ណជូនពរ ក្នុងឱកាសចម្រើនជន្មាយុ និងបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរចំនួន១២លើក

- បានចាត់ចែងផ្ញើសាររំលែកទុក្ខ និងរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធមន្ត្រីជាន់ខ្ពស់ និងឥស្សរជននានាចំនួន០៧លើក។

**៣- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- ឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបកម្មសិក្សាការីជនជាតិបារាំង-កាណាដា ចូលជួបសម្ដែងការគួរសម និងជម្រាបលា

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងកិច្ចប្រជុំអាស៊ានបូក៣ នៃមហាសន្និបាតសហភាពអន្តរសភា(IPU)លើកទី១៤២ ក្រោមប្រធានបទ "យកឈ្នះរោគរាតត្បាតថ្ងៃនេះ និងធ្វើឱ្យប្រសើរឡើងនៅថ្ងៃស្អែក ជាតួនាទីរបស់សភា" តាមប្រព័ន្ធវីដេអូ ព្រមទាំងចាត់ចែងជូនតំណាងអគ្គនាយកដ្ឋានស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ESCAP តាមប្រព័ន្ធវីដេអូ

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន០៩ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមេសាចំនួន០១ច្បាប់

- បានផលិតព័ត៌មានច្បាប់ជាតិ-អន្តរជាតិ និងនយោបាយចំនួន៦០អត្ថបទ

- បានទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា,ស្ថានទូតចិន,ស្ថានទូតម៉ាឡេស៊ី,ស្ថានទូតហ្វីលីពីន, វិទ្យាស្ថានសភាកម្ពុជា(PIC), ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រថៃឡង់ដ៍(Tica), វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT), ក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍វគ្គបណ្ដុះបណ្ដាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៤- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានទទួលលិខិតចូលចំនួន៩៤៦ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៧៤ច្បាប់

- បានសហការ សម្របសម្រួល និងរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ (ដូសទី១ និងដូសទី២)

ប្រកបដោយជោគជ័យ ព្រមទាំងបានគិតគូរ យកចិត្តទុកដាក់ រៀបចំបំពេញបែបបទជាមួយក្រសួងសុខាភិបាល ដើម្បីចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ជូនក្រុមគ្រួសារសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលរស់នៅក្នុងផ្ទះជាមួយគ្នា

- បានបាញ់ថ្នាំសម្លាប់មេរោគតាមអគារនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

- បានតាមដាន និងធ្វើបច្ចុប្បន្នភាពការប្រើប្រាស់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ របស់បណ្តាប្រទេសនានានៅលើពិភពលោកចំនួន០៤ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន

- បានប្រជុំរៀបចំផែនការការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចាត់ចែងរៀបចំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូស្តីពី ការត្រួតពិនិត្យការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងអំឡុងពេលនៃការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពី ការបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្តាល ដើម្បីចូលរួមបង្ការទប់ស្កាត់ជំងឺកូវីដ-១៩

- បានសិក្សាការរៀបចំវិទ្យាស្ថានសភាអាស៊ី(PCA) ដំណាក់កាលបន្ទាប់ពីវិទ្យាស្ថានសភាកម្ពុជា(PIC ) និងការរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្រប នឹងដំណាក់កាលថ្មី

- បានបើកប្រាក់បៀវត្សប្រចាំខែមេសា និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែមេសា ឆ្នាំ២០២១

- បានរៀបចំបែបបទប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗជូនសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ខែឧសភា និងខែមិថុនា ឆ្នាំ២០២១

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំតបណ្តាញប្រព័ន្ធ(FMIS) បំពាក់សម្ភារ ការប្រើប្រាស់ និងប្រជុំតាមប្រព័ន្ធវីដេអូ

- បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន២០ប័ណ្ណ

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន០៩ច្បាប់

- បានបង្កើតគណៈកម្មការដើម្បីពិនិត្យ និងសិក្សាអំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អង្គភាពកិច្ចការសុខភាព និងសង្គមកិច្ចនៃព្រឹទ្ធសភា

- កំពុងសាងសង់អគារ១ខ្នង កម្ពស់៣ជាន់ នៅខាងមុខអគារជប៉ុននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានបាំងកញ្ចក់ឆ្អឹងដែកសម្រាប់ធ្វើជាបន្ទប់ប្រជុំ នៅខាងមុខនាយកដ្ឋានស្រាវជ្រាវថវិកា

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានានាចំនួន០៦លើក/០៧ប្លង់

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យជណ្តើរយន្តត្រួតពិនិត្យសត្វកណ្តៀរ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹមបិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣១៧គ្រឿង/លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Ipad Smart Phone, ដាក់កម្មវិធីកម្ចាត់មេរោគUpdate Files Antivirus និងSetup Window Printer Program Ipad ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៤២គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន១១៥ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា ឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៨ច្បាប់

- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខា-

ធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន០៧លើក

- បានតុបតែងលម្អ និងតាំងពិព័រណ៍រូបភាពចំនួន០៧លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៩ច្បាប់ ស្មើនឹង៨៥នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន១៧៩លើក

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៦លើក មានអ្នកចូលរួមចំនួន១៦៨នាក់

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤សំណើ

- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព មានជំងឺ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៣នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន៣០០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន២៧សំណើ និងចងក្រងធ្វើជាសៀវភៅចំនួន១៩ក្បាល អស់ក្រដាសចំនួន១៥,៦៩០សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន៩៣លើក ស្មើនឹង១០៥នាក់

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមេសាចំនួន០៤ច្បាប់

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន១,៥៨៣លើក

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៤១លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៩លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០៨លើក។

**III-ទិសដៅការងារខែឧសភា ឆ្នាំ២០២១**

-បន្តចូលរួមអនុវត្តបម្រាមរាជរដ្ឋាភិបាលឱ្យម៉ឺងម៉ាត់ជាទីបំផុត ដើម្បីចូលរួមប្រយុទ្ធប្រឆាំងការរីករាលដាលជំងឺកាចសាហាវកូវីដ-១៩ តាមវិធានរបស់ក្រសួងសុខាភិបាល

-ត្រៀមសហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ជូនក្រុមគ្រួសារសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីឆ្លងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៦ និងទី៧ ព្រមទាំងពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅកាន់ព្រំដែនកម្ពុជា-ឡាវ

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីខេត្តបាត់ដំបងទៅកាន់ព្រំដែនកម្ពុជា-ថៃ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនដាយណា ណេសិនណល ហេរី ម៉ាស៊ីនណឺរី ឌបភើវេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃ លើអានុភាព ១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារ និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ចូលរួមកិច្ចប្រជុំ និងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាៈ

+នាំយកអំណោយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ផ្តល់ជូនរាជធានីភ្នំពេញ សម្រាប់ចែកជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត

+ពិធីសម្ពោធសមិទ្ធផលវត្តព្រៃកជ្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិវង្ស នៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

-ត្រៀមរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសរបស់ក្រុមសភា(APF)ជូនលោកជំទាវ ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំពិធីជំនួបសវនាការរវាងថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអគ្គទូតនានា

-ត្រៀមរៀបចំវិទ្យាស្ថានសភាអាស៊ី(PCA)

-ត្រៀមរៀបចំ និងចូលរួមប្រជុំ AIPA-Norway

-កិច្ចប្រជុំក្រុមសភាអាស៊ី-ប៉ាស៊ីហ្វិក និងមហាសន្និបាត IPU លើកទី១៤២

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ

-បន្តតាមដានវឌ្ឍនភាពនៃការរៀបចំប្រជុំ វេទិកាសភាអន្តរជាតិនានាដូចជា ASEP11

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ស្តីពី កិច្ចសហ-ប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាមួយរាជបណ្ឌិត្យសភាកម្ពុជា

-ត្រៀមរបាយការណ៍ចំណូល-ចំណាយថវិកាឆមាសទី១ ឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ត្រៀមធ្វើវិចារណកម្ម តាមសារាចរណែនាំស្តីពី ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ សម្រាប់អនុវត្តច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

-រៀបចំគម្រោងថវិកាឆ្នាំ២០២២របស់ព្រឹទ្ធសភា

-ត្រៀមរៀបចំយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល (ឆ្នាំ២០២២-២០២៤)

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែឧសភា ឱ្យបានទាន់ពេលវេលា

-ត្រៀមរៀបចំធ្វើបច្ចុប្បន្នភាពគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងថវិកាតាមកម្មវិធីលើមូលដ្ឋានរចនាសម្ព័ន្ធថ្មីរបស់អគ្គនាយកដ្ឋានទាំង៩

-បន្តសហការជាមួយក្រុមការងារ (FMIS) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការប្រើប្រាស់ និងបំពាក់សម្ភារប្រជុំតាមប្រព័ន្ធវីដេអូ

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-បន្តបណ្តុះបណ្តាលមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមកម្មវិធីរៀនពីចម្ងាយ

-បន្តការដ្ឋានសំណង់អគារកម្ពស់៣ជាន់ និងសិក្សាកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបច្ចេកវិទ្យាព័ត៌មាន

-ត្រៀមរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំថ្មី

-បន្តថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងបរិវេណព្រឹទ្ធសភា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង និងការគ្រប់គ្រងការប្រើប្រាស់ Internet

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានាៗលៗ)

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធOnline ដើម្បីធានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពជូនស្ថាប័នឱ្យបានល្អប្រសើរ

-រៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT) គ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារ

អេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-ត្រៀមលក្ខណៈចូលរួមពិធីបុណ្យជាតិសំខាន់ៗ៖ ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

**IV-សេចក្តីសន្និដ្ឋាន**

ក្នុងខែមេសានេះ កម្ពុជាស្ថិតក្នុងស្ថានភាពនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដែលតម្រូវឱ្យប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនទូទាំងសកលលោកចេះរស់នៅ និងការបំពេញការងារតាមគន្លងថ្មី ក្នុងបរិបទបិទខ្ទប់រាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ ដើម្បីបញ្ចៀសការឆ្លងជំងឺដ៏កាចសាហាវ។ ស្របពេលជាមួយគ្នានេះ ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា នៅតែបន្តយកចិត្តទុកដាក់យ៉ាងសកម្មលើមុខងារតំណាង ចុះសួរសុខទុក្ខ និងនាំយកអំណោយ ថវិកា ចែកជូនប្រជាពលរដ្ឋមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំចាត់ចែងកិច្ចប្រជុំអាស៊ានបូក៣ កិច្ចប្រជុំក្រុមសភាអាស៊ី-ប៉ាស៊ីហ្វិក(APG) ក្នុងក្របខណ្ឌមហាសន្និបាតសហភាពអន្តរសភា(IPU) លើកទី១៤២ តាមប្រព័ន្ធវីដេអូ និងចូលរួមកិច្ចប្រជុំ ESCAP។

ទន្ទឹមនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បាននាំយកអំណោយ និងថវិកាឧបត្ថម្ភជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលកំពុងធ្វើចត្តាឡីស័ក និងរស់នៅតំបន់ក្រហម ដើម្បីជួយសម្រួលការលំបាកក្នុងបរិបទនៃជំងឺកូវីដ-១៩ និងនាំអំណោយមនុស្សធម៌ជូនសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ ព្រមទាំងជានាការរៀបចំកញ្ចប់អំណោយសម្រាប់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ។

មន្ត្រីរាជការទាំងអស់ ត្រូវអនុវត្តបម្រាមរាជរដ្ឋាភិបាលឱ្យបានម៉ឺងម៉ាត់ជាទីបំផុត និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមជាមួយវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ថ្ងៃចន្ទ ១៤ រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១

**អគ្គលេខាធិការ**

**អ៊ុំ សារឹទ្ធ**